***គុណតម្លៃ***

*ការប្តេជ្ញាចិត្ត  តម្លាភាព  ភក្តីភាព*

*សេចក្តីសុចរិត និង  ភាពជាអ្នកបំរើ*

***ទស្សនៈវិស័យ***

*ប្រជាពលរដ្ឋមានទឹកប្រើប្រាស់សុខភាពអនាម័យ*

*និង បរិស្ថានល្អដើម្បីអោយជីវិតបានប្រសើរឡើង។*

# ការពិពណ៌នាការងារ

***បេសកកម្ម:*** *លើកកំពស់គុណភាពទឹក អនាម័យ សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងបណ្តាលសហគមន៍ គោលដៅដោយ ប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។*

## ១- *ការសង្ខេបអំពីមុខតំណែង*

| | |
|---|---|
| មុខតំណែង | **អ្នកស្ម័គ្រចិត្តត្រួតពិនិត្យចម្រោះទឹកស្អាតនិងអនាម័យសាលារៀន** |
| ទីតាំង | **ខេត្តព្រៃវែង** |
| ខ្សែររយៈរាយការណ៍ និង ទំនាក់ទំនង | ត្រូវរាយការណ៍ទៅអ្នកសម្របសម្រួលកម្មវិធីទឹកស្អាតនិងអនាម័យសាលារៀន។ ធ្វើការទំនាក់ទំនងជាប្រចាំជាមួយអ្នកទទួលផលក្នុងសហគមន៍ ដូចជានាយកសលារៀន-គ្រូបង្រៀន សិស្សានុសិស្ស-អ្នកស្ម័គ្រចិត្តភូមិ និង បុគ្គលិកអប់រំសុខភាពនិងអនាម័យសាលារៀន-ប្រធានគំរោងកម្មវិធីប្រចាំតំបន់នីមួយៗ-បុគ្គលិកក្នុងតំបន់ ។ |
| គោលបំណងនៃតួនាទី | ធ្វើការងារជាមួយគំរោងក្នុងសហគមន៍ -សាលារៀន ដើម្បីអោយមានការកើនឡើងនូវការប្រើប្រាស់ ទឹកស្អាតតាមរយៈ ការស្តារ ការត្រួតពិនិត្យ ការវាយតំលៃ ការតំឡើង ការបង្រៀនអំពីការប្រើប្រាស់ និង ការថែទាំចម្រោះទឹក។ |

## ២-ភារៈកិច្ចសំខាន

| **ការទទួលខុសត្រូវ** | **សកម្មភាពជាក់ស្តែងត្រូវអនុវត្តន៍។** |
|---|---|
| ត្រួតពិនិត្យចម្រោះទឹក | • ប្រមូលព័ត៌មានចម្រោះសាលារៀនមុនៗ (Functionality)<br>• រៀបចំសំភារៈ/ឧបករណ៍ (small tools) និងកំណត់ផែនការ ដើម្បីធ្វើការត្រួតពិនិត្យចម្រោះ<br>• ធ្វើការតំឡើងចម្រោះឡើងបើសិនជាចាំបាច់<br>• ត្រួតពិនិត្យបរិក្ខារចម្រោះ (WASH) និងថតរូប<br>• ចូលរួមការត្រួតពិនិត្យចម្រោះជាមួយអ្នកស្ម័គ្រក្នុងសហគមន៍ -សាលារៀន (ប្រសិនបើមាន)។<br>• ជំរុញនិងលើកទឹកចិត្តដល់នាយកសាលា -គ្រូបង្រៀន-សិស្សានុសិស្សអោយប្រើប្រាស់និងថែចម្រោះទឹកអោយបានត្រឹមត្រូវ។<br>• បង្រៀនអំពីការប្រើប្រាស់ និង ថែទាំចម្រោះដល់ នាយកសាលា-គ្រូបង្រៀន-សិស្សានុសិស្សក្នុងកំឡុងពេលនិងក្រោយត្រួតពិនិត្យចម្រោះទឹកតាមសាលារៀន |

| | |
|---|---|
| | គោលដៅ។ |
| តំលើងចំរោះតាមសាលារៀន | • ជួយសំរបសំរួលអ្នកដឹកជញ្ជូនសំភារៈតំឡើងចំរោះធំពីការិយាល័យខេត្តកំពង់ស្ពឺទៅកាន់សាលារៀនគោលដៅ<br>ដើម្បី ទុកដាក់និង តំឡើងចម្រោះទឹក។<br>• ជួយសំរួលក្នុងការតំឡើងចម្រោះទឹកក្នុងសាលារៀនតាមតំបន់គោលដៅ។<br>• ជួយសំរួលក្នុងការពិនិត្យ មើលនូវតំរូវការនៃការស្នើសុំខ្សាច់ពីគំពោងតាមខេត្តផ្សេងៗអោយបានទាន់ពេលវេលា។<br>• បង្រៀនដល់នាយកសាលា-គ្រូបង្រៀន-សិស្សានុសិស្ស នូវរបៀបលាងខ្សាច់និងត្រួតពិនិត្យ (តំឡើងជាថ្មី)។<br>• តំលើងចម្រោះជូន នាយកសាលា-គ្រូបង្រៀន- សិស្សានុសិស្ស ដែលប្រកបទៅដោយគុណភាព។<br>• បង្រៀនឡើងវិញដល់ គ្រូបង្រៀន-សិស្សានុសិស្ស នូវរបៀបថែទាំចំរោះ ការប្រើប្រាស់ នៅពេលដែល<br>តំឡើងចម្រោះនៅតាម សាលារៀននីមួយៗ។ |
| ទំនាក់ទំនង ក្នុង សហគមន៍ | • មានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានភូមិ/ឃុំ មន្ត្រីអភិវឌ្ឍន៍ភូមិ និងនាយកសាលា-គ្រូបង្រៀននិង<br>សិស្សានុសិស្សតាមសាលារៀនគោលដៅ។<br>• មានទំនាក់ទំនងល្អជាមួយក្រុមការងារ។<br>• សហប្រតិបត្តការត្រួតពិនិត្យចំរោះនៅតាមសាលារៀនគោលដៅរួមជាមួយសិស្សានុសិស្សនិង បុគ្គលិកអប់រំសុខភាពនិងអនាម័យសាលារៀននិមួយៗ។ |
| ភារៈកិច្ចផ្សេងៗ | • ភារៈកិច្ចផ្សេងៗដែលតំរូវដោយអ្នកគ្រប់គ្រងនិងក្រុមការងារ។ |

## ៣-លក្ខណៈសម្បត្តិដែលត្រូវមាន

| | |
|---|---|
| បទពិសោធន៍ការងារ | ធ្លាប់ធ្វើការជាមួយសហគមន៍កាន់តែប្រសើរ។ |
| ការសិក្សា | អាន និយាយ និង សរសេរភាសាខ្មែរបានល្អ។ |
| ជំនាញ | • ជំនាញបច្ចេកទេស។<br>• មានសមត្ថភាពក្នុងការសំរបសំរួលសហគមន៍។<br>• ធ្វើការងារដោយឯករាជម្ចាស់ការ និង មានគំនិតច្នៃប្រឌិត។<br>• មានសមត្ថភាពបង្រៀន-ពន្យល់ដល់សហគមន៍ អំពីការថែទាំ និងការប្រើប្រាស់ចំរោះដល់សិស្សានុសិស្សនៅក្នុងសាលារៀនគោលដៅ។<br>• សរសេររបាយការណ៍។<br>• ដឹងច្បាស់អំពីភូមិសាស្ត្រក្នុងតំបន់ប្រតិបត្តិការ។<br>• មានចំណេះដឹងក្នុងការប្រើប្រាស់និងបើកបររថយន្តបានកាន់តែប្រសើរ។ |

| | |
|---|---|
| បុគ្គលិកលក្ខណៈ | • ប្តេជ្ញាគោរពតាមបេសកកម្ម និង គុណតំលៃរបស់អង្គការ។<br>• ធ្វើការងារជាក្រុម។<br>• ចេះបត់បែន។<br>• មានឆន្ទៈក្នុងការធ្វើការងារជាមួយសហគមន៍។ |